Khmer Story Lovers

# បញ្ញាមរណៈ

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ហ្វាន់ជីជឿជាក់ថា មិនអាចចៀសផុតក្ដីមរណៈ ក៏ផុសបានទឹកចិត្តអង់អាច បោះជំហានដើរចេញយ៉ាងក្លាហាន ។ ស៊ីផាន និង ឈិនឈុងជី តាមកិតពីក្រោយ ។ មកដល់ក្រៅ នាងក្រមុំតាំងថៃស៊ើរ បើកភ្នែកមិនរួច តែទទួលអារម្មណ៍ដូចបានសម្លឹងទៀត និងហាក់មានកម្លាំងព្រឺស ។ ដើម្បីផ្គាប់ផ្គូរនាយក្រុម ឈិនឈុងជីស្ទុះទៅយកដាវប្រគល់ផ្ទាល់ដៃឲ្យមាណព ។ ស៊ីផានទទួលយក ហុចទៅឲ្យហ្វាន់ជីយ៉ាងគួរសម ។

អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ ៣៖០០

ផ្សាយចេញពីក្រុមអ្នកនិពន្ធ

«មាតុភូមិ»

ភ្នំពេញ

លេខ ១០

បុប្ផាភ្នំទឹកកកក្រែងរអែងការប្រគល់ដាវជាកលល្បិច សម្រាប់ឆ្កៀតវាយលុក ក៏ខំខិតឃ្លាតខ្លួនចម្រើនកម្លាំងមកផ្ដុំនៅដៃទាំងពីរ អាលង៉ឹងកញ្ឆក់ទាំងដាវទាំងស្រោមឲ្យបានរហ័សទាន់ចិត្ត ។ ឈុងជីដឹងនាងមានស្នៀតដាវចម្លែក ប្រញាប់ដណ្ដើមកាំបិតសេនាចូលមកជិតនាយក្រុម ដើម្បីការពារខ្លាចសិស្សភ្នំទឹកកកប្រព្រឹត្តមិនគប្បី ។

ស៊ីផាននិយាយឡើង :

– អ្នកនាងហ្វូ! មុខរបួសមិនអីទេឬ? បើប៉ាក់ផ្អើង ខ្ញុំអាចជួយបានដូចកាលខ្ញុំតដើងឲ្យអាវ៉ូងអ៊ុចឹងណា៎ ។

សំដីនេះហូរចេញពីមនោសញ្ចេតនា រំដើបរំជួលជ្រួលច្របល់

ខ្វល់ខ្វាយស្ដាយស្រណោះពេលពិតកាលសួរដំណឹង ។ តែអ្នកទៅទីនេះបែរជាយល់ច្រាសជើងទៅវិញ ។ ហ្វូហង់ជីជាស្រីក្រមុំ លុះឃើញគេសម្លឹងជើងមិនដាក់ភ្នែកដូច្នេះ នាងរឹងខ្លួន អៀនៗខ្មៀនក្រហមមុខមួយរំពេច ។ នាងជេរបន្ទោសថា :

– ឥតពូជឥតពង្សមែន ! និយាយស្ដីកំប៉ោកតាបដែរ !

ស៊ីផានសួរដោយឆ្ងល់ :

– ថាម៉េច ? សំដីនេះនិយាយមិនបានទេឬ ? ឲ្យខ្ញុំជួយមើលមុខរបួសឬ ?

នាយមានឫកពាដូចកូនក្មេង ហើយគ្មានបំណងអ្វីអាក្រក់ទេ តែនាងក្រមុំនៅតែយល់ថាគេចង់ឌឺដងខ្លួនដដែល ម្ល៉ោះហើយនាងដកដាវខ្វាក់ គំហក:

– នែ ! ជនត្រកូលស៊ី ! ឯងហ៊ានឈានចូលមកមួយជំហានទៀត ហើយនឹងប្ដូរជីវិតជាមួយឯងភ្លាម !

ផ្លែដាវត្រីត្រង់តបញ្ចេញរស្មីខៀវស្រងាត់ដាក់តម្រង់ទ្រូងស៊ីផាន ។ ឈិនឈុងជីសើចហាសហាពោល:

–អ្នកនាងហ្វូ ! នាយក្រមយើងមានរូបស្រស់សង្ហា បើគាត់ចាប់ចិត្តដិតអារម្មណ៍លើអ្នកនាង ពិតជាគួរសំណាងកម្មបានជួបណាស់ ! ពេលនេះទោះជាអ្នកនាងមានដាវក៏ដូចជាឥតដែរ ! ក្នុងវាលវដ្ដសង្សារដ៏ធំធេងនេះ ពុំដឹងជាមាននារីស្អាតឆ្លូវឆ្ងង់ពុំផានប៉ុន្មានទេ ដែលចង់ស្មោះស្នេហ៍ក្រំដរលោកនាយក្រម ប៉ុន្តែនារីទាំងនោះគ្មាននិស្ស័យបានមួយយប់ផងទេ !

ហ្វូហង់ជីតក់ស្លុតស្ទឹកស្ងាំង បញ្ចេញស្នៀត «ខ្យល់បក់វាលខ្សាច់» ចាក់ដើមទ្រូងស៊ីផានភ្លាមៗ

## វគ្គទី ១០

## គូព្រេងពីអតីត

ស៊ីផានមានកម្លាំងស្ទុកស្ទម្ភលើសគេមែន, តែនាយមិនដែលស្គាល់ការប្រយុទ្ធជាមួយអ្នកគុននិយម បានជាលេះលាំងរកច្រកគេចក្នុងពេលឃើញហ្វូហង់ជីយាត្រដាវចាក់មក ។ ឮសូរខ្យល់វូៗ នាយគេចផុតជិតជាប់ជំហានយ៉ាងរហ័ស ។ ហ្វូហង់ជីឥតនឹកស្មានថាគេគេចរួចដូច្នេះសោះ ថែមទាំងឃើញគេមានគុនសម្រាលខ្លួនខ្ពង់ខ្ពស់ផង ក៏ស្រឡាំងកាំងនិយាយលែងចេញ ។

ស៊ីផឆានកដៃញាប់ស្អេក :

–អ្នកនាងហ្វូអើយ! ខ្ញុំខ្លាចអ្នកនាងហើយ! មាត់និយាយគៀនឲ្យខ្ញុំសម្លាប់ តែអ្នកនាងបែរជាលើកដាវ តាក់ខ្ញុំវិញ! ណ្ហើយ! ចង់ទៅណាទៅចុះ,បើចង់នៅទីនេះក៏បានដែរ, ខ្ញុំលែងហ៊ាននិយាយចូលហើយ ។

នាយយល់ថាមានរឿងអីតាស់ចិត្តគេទើបគេលើកដាវតាក់ជួប្ចេះ ម៉្លោះហើយនិយាយច្រើនតាំងតែ ខូចការ, ចាំសួរគាយជាមុនសិន ។ ពេលបង់នាយបែរខ្លួនចេញដំណើរ, ហ្វូវាន់ជីរឹតតែឈ្លស់ ស្រែកខ្លាំងៗ :

– អីនាយក្រុមស៊ី ! ឯងលែងយើងមែន ឬប្រើសេនាចាំចាប់យើងមកវិញ ?

– ខ្ញុំប្រើគេចាប់នាងមកធ្វើអីទៀត ឲ្យនាងខឹងចិត្ត លើកដាវតាក់ខ្ញុំស្លាប់គាយហោងទៅឬ ?

ហ្វូវាន់ជីសង្ស័យណាស់មិនដឹងតើនាយក្រុមត្រកូលស៊ីមានកលល្បិចយ៉ាងណា ។ នាង នឹកថាត្រូវតាកចេញឲ្យផុតពីជំរំបិសាចនេះសិន យ៉ាងណាសឹមយ៉ាងហ្នឹងចុះ ។ នាងវិល ក្អែកសម្លក់ស៊ីផឆានបន្តិចទើបស្ទុះគេចទៅ ។ ឈិនឈុនជីសើច :

– ជំរំក្រុមឈានឈ្លួចមែនពិត តែមិនខ្វះអ្នកយាមទេ, នាងហួចង់ចេញចូលជំរំយើងតាមអំពើ ចិត្ត ស្មានថាពួកយើងជាទីងមោងចាំចាបឬ?

ហ្វូវាន់ជីជ្រួញចិញ្ចើម :

– ឯងចង់យ៉ាងម៉េច ?

ឈិនឈុនជីសើច :

– យើងគិតថាត្រូវជូនដំណើរនាងចេញទៅទើបបាន ។

ហ្វូវាន់ជីគិតថា យើងនៅក្រោមដំបូលគេត្រូវឱនក្បាលបន្តិចអីចឹងហើយ មកពីយើងមើល ងាយសត្រូវពេកទើបប្លោះខ្លោយរហូតគេចាប់បានដូច្នេះ ។ គិតទៅចង់ចូលរុកឡុកក្រុមឈានឈ្លួ មិនមែនជាការងាយទេ, ពេលនេះគោងអត់ទ្រាំបន្តិចសិនចុះ, ចាំប្រមូលបងប្អូនមកលើកក្រោយ ទៀត លាងកិត្តិយសឲ្យតាល់តែបាន ។

គិតឃើញដូច្នេះនាងឆ្លើយ :

– សូមអរគុណលោកនាយត្រួតណាស់ ។

ឈិនឈុនជីបែរបើលស៊ីផឆាន :

- លោកនាយក្រុម , ខ្ញុំសូមជូនដំណើរនាងទៅក្រៅ ។

ស៊ីផធានងក់ក្បាលឆ្លើយយ៉ាងប្រញាប់ថា ល្អ ! ល្អ !

នាយឆ្លើយយ៉ាងរហ័សព្រោះញញើតស៊ីផាវហួវ៉ាន់ជីណាស់,មិនហ៊ានឈរជិតយូរ គឺឲ្យឈិនលុងជីជូននាងចេញទៅ ។ នាយបែរក្រោយដើរទៅកាន់បន្ទប់វិញ ជួបមនុស្សម្នាតាមផ្លូវហូត ហើយអ្នកអស់នោះឃើញនាយពីចម្ងាយ តែងតែគេចចុកផ្លូវឲ្យនាយដើរជានិច្ច ។ ចូលដល់បន្ទប់ នាយឃើញតាយធានឈរចាំយ៉ាងសុភាព ម្ហូបអាហាររៀបចំហើយស្រេច ដាក់ពេញលើតុ ។

ស៊ីផធានមិនបេះគួរសមច្រើន,អង្គុយប៉ុកបរិភោគយ៉ាងឆ្ងាញ់,ពោលសរសើរជាប់មាត់ ។ បរិភោគបាយរួចហើយ អ្នកកម្លោះចង់សួរតាយធានអំពីរឿងហេតុដែលនាយត្រួតសិន្ធុកំណាច ចាប់បានហួវ៉ាន់ជីនិងរឿងនាងនេះណើកជាវេកសម្លាប់នាយ ស្រាប់តែលាន់សម្លេងអ្នកយាមស្រែកប្រាប់មុន :

- លោកគ្រូពៃ អញ្ជើញមកដល់ហើយ !

ស៊ីផធានរីករាយណាស់ ស្ទុះចេញទៅទទួលគាត់ឯបន្ទប់ទទួលភ្ញៀវក្លាម ហើយពោល :

- លោកគ្រូពៃអើយ , អម្បាញ់មិញខ្ញុំប្រទះរឿងមួយចំឡែកណាស់ ។

ពោលហើយនាយរៀបរាប់រឿងថ្មី ៗ ដែលកើតឡើងក្នុងទីឃុំឃាំងប្រាប់ពៃហាស៊ីទាំងអស់ ។ លោកគ្រូពេទ្យងក់ក្បាលមួយ ៗ ហើយធ្វើមុខមាំពោល:

- ខ្ញុំបាទមកនេះមានគោលបំណងមួយសំខាន់ដែរ សូមលោកនាយក្រុមអភ័យទោសផង ។ លោកនាយត្រួតឈិនបំពើក្រុមបក្សដោយក្តីស្មោះត្រង់ , សូមលោកលើកលែងទោសឲ្យគាត់ម្តងទៅ ។

ស៊ីផធានសួរដោយឆ្ងល់:

- លើកលែងទោសឲ្យគាត់ ? ម៉េចលោកគ្រូមានប្រសាសន៍ដូច្នេះ? គាត់ល្អណាស់ ។ បើមានជម្ងឺអ្វីសុំលោកជួយមើលគាត់ផង ។

ពៃហាស៊ីលំអោនកាយទាំងរីករាយ :

- សូមអរគុណលោកនាយក្រុមជាអនេក ។

គ្រូពេទ្យដៃធេតធ្លាប់ស្គាល់ចិត្តនាយក្រុមណាស់, បើគាត់ចង់ដាក់ទោសនរណាហើយ គាត់មិនងាយទទួលអន្តរាគមន៍ដោះលែងឡើយ ។ ថ្ងៃនេះគាត់ប្រែចិត្តមកសួគតបបេះប្រណីគេប្រហែលគាត់

យោគយល់យើងហើយ ។ ពៅហៃស៊ីប្រញាប់លាទៅវិញភ្លាមដើម្បីរកថ្នាំបន្សាបជួយ ព្យាបាល នាយគ្រួគលិនលុងជីក្រេងហានផ្លូវគង់វង់ជីវិត គ្រាន់ជួយទ្រទ្រង់ក្រុមឈានលួតទៅទៀត ។

ត្បិតគលិនលុងជីជួនដំណើរហួសរាន់ដីចេញផុតពីភ្នែកប្រមុះអ្នកយាមកាលណា គាត់រួតរះទៅរកគ្រូពេទ្យដៃឆើតភ្លាម ពឹងឲ្យជួយអង្វរលោកនាយក្រុមសុំថ្នាំបន្សាបពិស ។ ពៅហៃស៊ីមិនស្មានថាហាមាត់ភ្លាមលោកនាយក្រុមយល់ព្រមភ្លាមដូច្នេះទេ ។

ចំណែកនៅក្នុងបន្ទប់ ស៊ីផាន់កំពុងសាកសួរកិច្ចការផ្សេង ៗ ក្នុងក្រុមឈានលួ ពីតាយផាន ។ នាយបានដឹងថាទីនេះជាស្រុកយានចូវកន្ទែងពាក់កណ្ដាលរបស់ក្រុមឈានលួ ។

នាយក្រុមឈានលួមានសហការីជំនិតប្រាំបីនាក់រាប់ទាំងពៅហៃស៊ីផង ហើយអ្នកអស់នេះសុទ្ធតែខ្លាំងពូកែ បានសេចក្ដីថាក្រុមឈានលួមានអំណាចធំធេងនិងសមាជិកច្រើនណាស់ ។ រីឯការទាក់ទងឬគំនុំរវាងក្រុមឈានលួនិងក្រុមដទៃទៀតក្នុងពិភពគុន តាយផានមិនដឹងទេ ព្រោះនាងមាននាទីបំរើលោកនាយក្រុមផ្ទាល់ប៉ុណ្ណោះឥតយល់កិច្ចការកាចកំបាំងក្នុងក្រុមឡើយ ។ ស៊ីផាន់វៃឆ្លាតយ៉ាងណាក៏មិនយល់កិច្ចការក្រុមបក្សនេះក្នុងពេលដ៏ខ្លីបានដែរ, នាយសញ្ជឹងគិតបន្តិចដឹងតែរឿងម្យ៉ាងថាពួកគេប្រឆាំងនាយក្រុមហើយ ទើបពោលប្រាប់នាងតាយផាន :

–បងតាយផា ! ពួកអស់នេះច្បាស់ជាប្រឆាំងហើយ, ខ្ញុំមិនមែនយល់សប្ដិទេ ។ លោកនាយក្រុមពួកបងជាមនុស្សផ្សេងពីខ្ញុំ ព្រោះខ្ញុំធ្លាប់នៅព្រៃភ្នំជាមួយម៉ែមិនដែលមាននរណាហៅនាយក្រុមអីទេ ។

តាយផានសើច:

–ក្នុងលោកយើងនេះ មានមនុស្សដូចគ្នាដែរតែមិនដូចបេះបិទទេ ។ ពេលនេះអ្នកប្រុសហាត់រៀនវិជ្ជាថ្មីពូកែចំឡែកបានសម្រេចផលទើបរញ្ជួយដល់គ្រឿងវិញ្ញាណនិងខួរក្បាល ។ ឥឡូវអ្នកប្រុសកុំគាលគិតច្រើនពេក សំរាកបន្តិចទៀតចុះ, មិនយូរមិនឆាប់គង់នឹកឃើញរឿងរាវម្ដងមួយៗពុំខាន ។

–ខ្ញុំថានឹកមិនឃើញទៀតទេ ។ ឥឡូវសុំសួរបងមួយទៀតមើល ហេតុអីបងមកបំរើខ្ញុំ ?

តាយផានក្រហមភ្នែក :

– ត្រូវស្រីបំរើមិនមែនធ្វើដោយចិត្តបងទេអ្នកប្រុសអើយ ! ខ្ញុំជាក្មេងកំព្រាតាំងពីតូចគ្មាននរណាចិញ្ចឹមបីបាច់រក្សា ទើបគេនាំមកឲ្យក្រុមឈានលួ ។

ស៊ីផាន់បន្ត :

– បើអ៊ីចឹងនាងមិនសប្បាយចិត្តទេ, ទៅវិញចុះមិនបាច់បំរើទេ, ខ្ញុំធ្វើកិច្ចការផ្ទះខ្លួនឯងបានទាំងអស់ ៗ

គាយផានពោលដោយអន្ទះអន្ទែង :

– ខ្ញុំគ្មានញាតិមិត្រម្នាក់សោះ តើអ្នកប្រុសឲ្យខ្ញុំទៅទីពឹងអ្នកណា ? ម៉្យាងទៀតបើគេដឹងថា ខ្ញុំមិនបន្តបំរើអ្នកប្រុស គេច្បាស់ជាធ្វើបាបខ្ញុំស្លាប់ហើយ !

– មិនអីទេ , ចាំខ្ញុំប្រាប់មិនឲ្យពួកគេធ្វើបាបនាង ៗ

គាយផានគ្រវីក្បាលបន្តថា :

– អ្នកប្រុសមិនទាន់ជាស្រួលបួលខ្ញុំមិនអាចទៅណាចោលទេ ៗ ឲ្យតែអ្នកប្រុសមិនធ្វើបាប ខ្ញុំសុខចិត្តនៅបម្រើរហូត !

– ម៉េចក៏ថាខ្ញុំធ្វើបាបនាង ? ខ្ញុំជាមនុស្សមិនដែលធ្វើបាបគេទេណា !

គាយផានទឹកខឹនផងចង់សើចផង ពោលថា :

– អ្នកប្រុសមានប្រសាសន៍ដូច្នេះ អ្នកឯទៀតច្បាស់ជាយល់ថា លោកនាយក្រុមស៊ីកៃប្រែចិត្តគំនិតមករកផ្លូវល្អវិញហើយ !

ស៊ីផាននឹកម្នាក់ឯងថា លោកនាយក្រុមស៊ីអីគេនោះច្បាស់ជាកាចសាហាវណាស់ ហើយចូលចិត្តធ្វើបាបគេបានជាគេខ្លាចញ័រគ្រប់ពេលវេលា ... ចំណែកយើងជាអ្នកណា ? គិតធ្វើដូចម្ដេចទៅ? ហ៎ ! ស្អែកនេះត្រូវតែប្រាប់លោកគ្រូពេទ្យបានច្បាស់លាស់ថា ពួកគាត់ប្រឡំមនុស្សហើយ !

មួននាយនឹកថាធ្វើនាយក្រុមឲ្យគេស្ដាប់បង្គាប់ដូចជាសប្បាយម៉្យាងដែរ មួននាយយល់ថាកូនឈ្នួលអ្នកដទៃដូច្នេះមិនស្រួលទេ កាលណាលោកនាយក្រុមពិតប្រាកដ ត្រឡប់មកវិញ ច្បាស់ជាទីនគ្រោះថ្នាក់ខ្លួនពោលមិនខាន ៗ

ស៊ីផានស្រស់ស្រូបបាយល្ងាចហើយ នាយអង្គុយនិយាយលេងជាមួយនាងគាយផានអំពីកិច្ចការថ្ងៃកៗក្នុងក្រុមប័ក្សដែលនាយមិនទាន់ដឹង ៗ ដល់ពេលយប់នឹកគាយផានក្រែនវៃអង្គលោកនាយក្រុមស្រែកឃ្លានគណ្ហាដូចមុនៗក៏ម្ចាសុំលាទៅបន្ទប់នាងក្បែរនោះព្រមទាំងទាញទ្វារបិទជិតផង ៗ

ស៊ីផានអង្គុយលើគ្រែ អផ្សុកណាស់ ៗ នាយចំរើនកម្លាំងធាតុតាមរូបគក្កតា ឈើម្ដងទៀតស្រាប់តែព្ញូស្ទូរក្រឹកៗ . . . នាយបើកក្នុកមើលកន្ទេនព្ញូស្ទូរឃើញបង្អួចរបើកសនិម្យ ហើយឃើញដៃមួយសម្រលុកៗលូកតាមបង្អួចមកបោយហៅនាយៗ ឃើញគេពាក់កាវៃបគងវែបស្រពិច

ស្រពិល ៗ ស៊ីផានភ្ញាក់ព្រើត ស្ទុះក្រោកដល់បង្អួចភ្លាមព្រោះនាយសែនទឹកនារីការបែកគង ៗ ទៅដល់នាយស្រែកហៅតិចៗ:

– បងស្រី !

សម្លេងនៅខាងក្រោយធ្វើហ៊ុះគបវិញ:

– ម៉េចក៏ហៅបងស្រីទៅហើយ ? ចេញមក !

ស៊ីផានលោតតាមបង្អួចចេញដល់ក្រៅឥតឃើញមនុស្សសោះ ៗ កំពុងឆ្ងល់ ស្រាប់តែមានដៃមួយត្រជាក់ស្រិបចន់ល្មើយចំចង្កេះនាយជិត ហើយមានសំណើចក្អឹក ១ លាន់ពីក្រោយខ្នង ជាមួយក្លិនក្រអូបសាយធ្លុលប្រមុះ ៗ ស៊ីផានអរណាប់ជឿជាក់ច្បាស់ថា នារីនេះកំពុងប្រឡែងលេងជាមួយនាយហើយ ៗ អ្នកកម្លោះធ្លាប់សំគ្នាំព្រៃភ្នំជាមួយការ្ជ័យហ៊ានកំសត់ ឥឡូវបានមនុស្សដូចគ្នាប្រឡែងលេង នាយសប្បាយក្រៃលែង ងាកក្រោយឱបគេវិញភ្លាម ព្រមទាំងពោល:

– មើលខ្ញុំចាប់នាងវិញបានស្រេច ៗ

នាយប៉ះសដៃ តែនៅទាញនារីពាក់ការបែកគង ព្រោះចាប់ត្រូវខ្យល់ទទេ , ស្រមោលបែកគង លោតក្រោកនៅពួនក្រោយគុម្ពផ្កា ៗ អ្នកកម្លោះលូកដៃចាប់ទៀត ចំបន្ទក្តាកុលាបស្រែកយ៉ូយ ! នារីងើតក្បាលមកពីគុម្ពផ្កាម្នាងសើចខឹក ១ :

– អន់ណាស់ ! កុំមាត់ខ្លាំងណា៎ ! មកតាមខ្ញុំភ្លាម !

ស៊ីផានឃើញនារីនោះបង្ហើរខ្លួនស្រាលស្មើកល្បឿនវ៉ែវ កំប្រញាប់ដេញតាមនាងដល់កៀនរបង ៗ នារីហៀបលោតផ្លោះរបងស្រាប់តែមានមនុស្សពីរនាក់ហក់ពីចំងងឹតឃាំងផ្លូវជាប់ ម្នាក់កាន់កាំបិត ម្នាក់កាន់ដក់ព្រមទាំងគំហកដាក់:

–ឈប់សិន! អ្នកណា?

ស៊ីផានមកដល់ល្មម ៗ ជនទាំងពីរត្រូវវេនយាមល្បាតការពារលោកនាយក្រុម, ឃើញស៊ីផានកំប្រដេញលេងជាមួយនាងដូច្នេះក៏ចប់ដំណើរលំពែងកាយគោរព ហើយដកខ្លួនទៅឈរសងខាងពោលទាំងញញើត :

– ខ្ញុំបាទមិនស្គាល់មិត្តលោកនាយក្រុម, សូមអភ័យទោស ៗ

នារីលៀនអណ្ដាតបោយដៃហៅស៊ីផាន់ទៀត រួចបង្វិលខ្លួនលោតផ្លោះរបងវិញ ។ អ្នកកម្លោះ ដឹងថាមិនអាចលោតដូចនាងបាន, តែនៅចំពោះមុខសេនានាយមានចិត្តអៀនខ្មាសដែរក៏មិនហ៊ានប្រើគេយកជណ្ដើរមកដាក់ឲ្យឡើង ។ នាយទ្រាំដើរតាមកញ្ញាការវៃបែតង លោតដល់កំពែងភ្លាម ដូចមានកម្លាំងសម្ងាត់ជួយរុញគូទឲ្យស្រាលស្ញើក ។ ដល់លើរបងហើយ នាយលោតវីងចុះដីទៀត បណ្ដាលឲ្យសេនាទាំងពីរកោតសរសើរពោលជំណាលគ្នាថាពូកែមែន ។

មិនទាន់ផុតមាត់ គេឮសូរគ្រាំងដូចមានវត្ថុជ្រុះទៅដី គឺស៊ីផាន់មិនចេះទប់កម្លាំងបណ្ដាលឲ្យធ្លាក់ដល់ដីដួលបះជើងនោះឯង ។ គេមើលមុខគ្នាមិនមាំងឥតហ៊ានស្មានថា លោកនាយគ្រូមដួលអុកគូទលើស្មៅខាងក្រៅទេ ព្រោះអម្បាញ់មិញឃើញលោកបញ្ចេញយុទ្ធសិល្បៈចំឡែកណាស់ៗ នៅខាងក្រៅនារីការវៃបែតងមើលឃើញច្បាស់, នាងភ្ញាក់ព្រើតសម្លឹងឆ្ពឹង ។ លុះឃើញអ្នកកម្លោះក្រោកមិនរួច នាងស្ទុះទៅជួយលើក ព្រមទាំងពោលសួរ :

- បងឈឺយ៉ាងម៉េចហើយ ? មិនទាន់ជាស្រួលបួលផង នៅចចេសធ្វើតាមខ្ញុំឬ ?

ស៊ីផាន់អុកគូទចល់ផ្អកឈឺណាស់តែបាននារីជួយលើក នាយខំក្រោកឈរយ៉ាងរហ័ស ។ នារីពោល:

-យើងទៅលេងកន្ទ្រែងដដែលណា ! បងឈឺទេ ? ដើររួចឬមិនរួច ?

ស៊ីផាន់នៅក្មេងកម្លាំងពេញបរិបូណ៌ថែមទាំងរៀនចេះយុទ្ធសិល្បៈថ្មីៗ ទើបអាចទប់ទល់ការឈឺចាប់បន្តិចបន្តួចបានយ៉ាងងាយ ។ នាយឆ្លើយយ៉ាងក្លាហានថា:

- មិនអីទេ, អាចដើរបាន ។

នារីទាញដៃអ្នកកម្លោះមកជិត សួរតិចៗ :

- ខានជួបមុខគ្នាយូរថ្ងៃហើយ, បងមានខឹងខ្ញុំដែរ ?

នាងសួរផង ងើបសម្លឹងមុខស៊ីផាន់ផង ដោយអាការៈស្រឡាញ់ពេញចិត្ត ។ អ្នកកម្លោះឃើញនារីរូបល្អមុខស្រស់ប្រិមប្រិយញញឹមដាក់ហើយនិយាយកក់កោះបែបនេះ ទោះល្ងង់យ៉ាងណាក៏ចេះកម្រើកចិត្តដូចកម្លោះឯទៀតដែរ ។ នាយសម្លឹងភ្នែកទាំងគូខ្មៅក្រឡុប, ចំពុះញញឹមមូលខ្ញង់ បបូរមាត់ក្រហមព្រឿងៗ ញញឹមជាប់ ក៏ញញឹមតបវិញហើយឆ្លើយ :

- យប់មុននាងមកមើលខ្ញុំតែមួយភ្លែតគេបាត់ភ្លាម ! ខ្ញុំនឹករឭកណាស់ !

នារីច្របាច់ដៃមាណពថ្នម ៗ:

- បងបាត់ខ្លួនយូរណាស់, គេនាំបងមកដល់នេះ បងនៅតែសន្លប់ច្រើនថ្ងៃទៀត។ ខ្ញុំភ័យណាស់ តែងលបមើលបងរាល់យប់, បងឥតដឹងទេព្រោះខ្ញុំឃើញបងរវល់ហាត់វិជ្ជាយុទ្ធសិល្ប: ទើបមិនហ៊ានហៅ ។

ស៊ីផានពោលទាំងរីករាយ :

- មែនឬ? ខ្ញុំឥតដឹងទាល់តែសោះ រវល់ហាត់ពេក ៗ ។ បងស្រីអើយ! ម៉េច...ម៉េចបងល្អម្ល៉េះ?

នារីប្រែទឹកមុខ រលាស់ដៃចេញភ្លាម ពោលបន្ទោស :

- បងហៅខ្ញុំថាម៉េច? ហ៊ឺះ! បាត់យូរអ៊ីចឹង ខ្ញុំស្មានដឹងអស់ហើយ បងឯងច្បាស់ជាទៅទាក់ទងនឹងនារីណាក្រៅពីខ្ញុំមិនខាន ។ ហ៊ឺះ! ហៅគេបងស្រី ៗ ទាល់តែរត់មាត់, ត្រឡប់មកវិញហៅខ្ញុំបងស្រីដែរ ប្រយ័ត្នណា!

នាងលែងសើចបែរជាខឹងក្រហមមុខភ្លាម ។ ស៊ីផានស្រឡាំងកាំងនិយាយឥតចេញក្រៅពីពាក្យថាខ្ញុំ... ខ្ញុំ.. បណ្ដាលឲ្យនារីខឹងខ្លាំងឡើងលើកដៃម្ជុលស៊ុកត្រចៀកមាណព បន្ទោស:

- ម៉ោកតាំងពីយូរណាស់មក បងនៅជាមួយស្រីណា? បងឯងហៅវា បងស្រីៗ មែនទេ? ប្រាប់ឆាប់ឡើង!

សួរបណ្ដើរនាងម្ជុលស៊ុកត្រចៀកខ្លាំងឡើងបណ្ដើរ ធ្វើឲ្យស៊ីផានឈឺពេកស្រែកថា:

- បើនាងកាចម៉្លឹងៗ ខ្ញុំមិនហ៊ានលេងចូលទេ!

នារីម្ជុលថែមមួយដំណាក់ទៀត កំញើញ:

- បងឯងចង់បោះបង់ខ្ញុំចោលឬ? មិនងាយដូចចិត្តទេ! នៅជាមួយស្រីណាប្រាប់ឆាប់មក!

ស៊ីផានញញឹមស្ងួត:

- ខ្ញុំនៅជាមួយស្រីព្រៃកំបែន... មានលេកវិតខ្ញុំ..

នារីខឹងតូចម្ជុលស៊ុកត្រចៀកនាយចេញឈាមរំប ៗ ស្ទើរដាច់ពីក្បាល ហើយនិពោល :

- មិនអីទេ, ខ្ញុំលេងបង បន្តិចសិន!

មាណពភ្ញាក់ព្រើតស្រែក :

- អីយូយកុំកាចពេក! កុំធ្វើបាបបងតាយជាននាងអើយ ! គាត់ផាំផ្ចាំលើកកម្ទាំងឲ្យខ្ញុំផឹក ហើយផាំបបរឲ្យខ្ញុំស៊ី. .បបរខ្វាចមែនតែគាត់ជាមនុស្សល្អ, កុំសម្លាប់បងតាយជានខ្ញុំ...អាណិតគាត់ផង !

នារីចិនស្រក់ទឹកភ្នែកតត់ ៗ ស្រាប់តែសើចផាក់ផ្អុកកម្ទោះ ព្រមទាំងទាញត្រចៀកនាយម្តងទៀត ពោល :

- ហ៊ឹះ ! ខ្ញុំស្មានតែដេកនៅជាមួយស្រីណា ! បងឯងមិនកុហកទេឬ ? កល់យប់ខ្ញុំតែងលបមើល តតដែលឃើញបងឯងធ្វើផ្តេសផ្តាសជាមួយស្រីបំរើនោះទេ ។ ឥឡូវជឿបងឯងម្តងចុះ !

ពោលរួច នាងលើកដៃកាន់ស្ទឹកត្រចៀកនាយទៀត ។ ស៊ុផឆានក្អាក់ព្រើតផ្អៀងក្បាលគេចភ្លាម , ទាំរអៀលត្រចៀកផ្អកកម្ទោះសើចស្រស់សួរថា ឈឺទេ ?

-ឈឺណាស់លោកអើយ !

- អីចឹងទើបសមមុខបងឯង ! ម៉េចកុហកខ្ញុំហើយ « កាប់កង » ហៅខ្ញុំស្ទូវតែបងស្រី ?

ស៊ុផឆានសើច :

- ម៉ែខ្ញុំតែងប្រដៅថា ហៅគេបង ៗ ទើបរាក់គួរសមណាំ ! ចុះខ្ញុំនេះខុស ឬ ?

នារីសម្លក់ផងញញឹមខ្ចឹបផង :

- នរណាឲ្យបងគួរសមជាមួយខ្ញុំ ? ឥឡូវបើចឹងណាស់ មួលស្ទឹកត្រចៀកខ្ញុំវិញមក !

ពោលផងនាងហុចត្រចៀកទៅផង ផ្សាយក្លិនក្រអូបសាយផល់ខ្ពប្រមុះមាណព, មាណពលើកដៃកាន់ត្រចៀកនាងថ្នម ៗ គ្រវីក្បាល :

- ខ្ញុំមិនមួលទេ !

នាយដកដៃចេញរួចសួរនារីទៀត:

- ឥឡូវ ប្រាប់ផងមើលឲ្យខ្ញុំហៅដូចម្តេចវិញ ?

នារីធ្វើប្ញកម៉ិកម៉ក់ :

- មុនៗ បងហៅខ្ញុំយ៉ាងម៉េច ? បងភ្លេចទាំងឈ្មោះខ្ញុំទៅហើយឬ ?

ស៊ុផឆានខំរៀបចំទឹកមុខពោលដោយម៉ឺងម៉ាត់:

-សុំប្រាប់អ្នកនាងតាមត្រង់ចុះ នាងប្រឡំហើយ ។ ខ្ញុំមិនមែន«បងឆាន» ហើយមិនមែនស៊ុផឆានទេ, ខ្ញុំឈ្មោះ ថ្កតពូជណាំ !

នារីស្រឡាំងកាំងលើកដៃចាប់ស្មានាយបង្វិលមុខ ឲ្យត្រូវពន្លឺព្រះច័ន្ទ ផ្ទៀងផ្ទាត់មើលមួយស្របក់ ទើបសើចហាសៗ :

- បងបានប្រសប់កំប្លែងមែនអម្បាញ់មិញនិយាយដូចជាពិតប្រាកដណាស់ ធ្វើឲ្យខ្ញុំភ័យស្មានថាច្រឡំមនុស្សមែន . . . ឥឡូវឈប់និយាយរឿងហ្នឹងទៅ . . .

នាងទាញដៃមាណពតែទៅមុខទៀត, ស៊ីផានស្រែកតវ៉ាភ្លាម :

- ខ្ញុំមិនមែននិយាយលេងទេ, នាងច្រឡំមនុស្សមែនណា ! ម៉េចមិនគិតមើល គ្រាន់តែឈ្មោះនាងក៏ខ្ញុំមិនដែលស្គាល់ដែរ ។

នារីចប់ដំណើរងាកមកចាប់ដៃបុរសទាំងសងខាងពោលទាំងរីករាយ :

- បងចង់ធ្វើបាបខ្ញុំ, ចង់សងសឹករឿងស្ទូកត្រចៀកអម្បាញ់មិញឬ ? នែ ខ្ញុំមានត្រកូលចិនឈ្មោះ គុង, បងឯងធ្លាប់ហៅខ្ញុំថា ចិន ៗ ឬ គុង ៗ ...ជួនកាលហៅចិនគុងៗ ផង, បងចាំទេ ?

ពេលចប់នាងបែរក្រោយតែត្រឡប់ ទាញទាំងដៃស៊ីផានឲ្យទ្រេតទៅមុខរះដួលផង ៗ អ្នកកម្លោះខំរត់តាមក្រោយនាងភ្លាម ៗ មុនដំបូងនាយហត់គយូរហាក់អស់កម្លាំងណាស់, ក្រោយមកកម្លាំងជាតុក្កតាខ្លួនធ្វើចលនាស្រួលបួល នាយចាប់អារម្មណ៍ហាក់ស្រាលឡើង ៗ មិនបាច់ខំក៏អាចរត់លឿនដូចស្រមោលដែរ ៗ មួយសន្ទុះនាយដេញតាមនាងចិនគុងដល់មាត់ស្ទឹងថ្លាថ្លង់ឃើញស្រមោលព្រះចន្ទច្បាស់ពែស ៗ នារីចាប់ដៃនាយលោតផ្លោតចុះទូកតូចមួយ ដែលនៅមាត់ច្រាំងស្រាប់ ៗ

ស៊ីផានមិនទាន់បេះបញ្ហាកម្លាំងកាយក្នុងខ្លួនទេ, លោតទៅដល់ក្ដារទូកលាន់គ្រាំស្ទើរប្រេះជាពីរ ទឹកស្ទឹងបែកសំពោង ៗ ចិនគុងលាន់មាត់ :

- បងឯងចង់ធ្វើឲ្យលិចទូក ឬ ?

ពេលផងនាងចាប់ច្រវ៉ាមួយដើម.ដាលកូនទូកចេញទៅផង ៗ ទឹកស្ទឹងរលកកក្រាញ់ ៗ គួរគយគន់ ៗ មាណពសង្កេតមើលមាត់ស្ទឹងទាំងសងខាងឃើញផ្ទះអ្នកស្រុកមួយ ៗ, ដកដង្ហើមពេលណាធុំក្លិនក្រអូបសាយ ក៏និតថា :

- អ្នកស្រុកនេះ ដាំផ្កាគ្រប់គ្នាឬមួយក្លិននេះចេញមកពីខ្លួនប្រាណចិនគុង ?

កូនទូកបេះបៀនលយទៅមុខសន្សឹមៗ បត់ក្បួសព្រៅយពីរបីទើបដល់បឹងមួយតូច ៗ ចិនគុង

បត់ទូកចូលក្រោមស្ពានថ្ម ហើយចងទូកនឹងដើមឈើ ។ ទីនេះមានរុក្ខាច្រើនដុះបិទបាំងស្ពានជិតបាត់ សូម្បីពន្លឺព្រះច័ន្ទក៏បាំងមិនដល់កូនទូកនៅខាងក្រោមដែរ ។ ស៊ីផានសរសើរ:

- កន្លែងនេះស្ងាត់ល្អណាស់ ! បើប៉ះពេលថ្ងៃប្រហែលគ្មាននរណាដឹងថា នៅក្រោមស្ពានមានទូកនេះទេ ។

ទីងតុងសើច:

- ម៉េចទើបពោលសរសើរក្នុងយប់នេះ, មុន ៗ មិនហើបមាត់ផង ?

នាងពោលហើយចូលក្នុងទូកយកកន្ទេលមកក្រាលព្រម ទាំងយកចាន, ចង្កឹះនិងប៉ានស្រារៀបចំលើកន្ទេលហើយបបួលមាណព :

- អញ្ជើញលោកបងនាយក្រុមពិសាស្រាសិន !

នាងលើកបានសណ្ដែកដីលីង និងសាច់ងៀតដាក់ពីមុខស៊ីផានឲ្យនាយក្រុមស្រា ។ មាណពផឹកស្រាឈ្ងុយឈ្ងប់ហើយក្រអូបគួរឆ្ងាញ់ណាស់ តែមិនដែលសាកល្បងទេ គ្រាន់តែធ្លាប់ឮម្ដាយពោលញយៗថាផឹកស្រាៗ ។ ស្រានាងទីងតុងក្រអូប ហើយមានពណ៌លឿងខ្ចីផឹកមួយក្រេបទៅក្ដៅពោះដំ ហុំរបន្តិចល្វីងបន្តិច ។ ស៊ីផានជ្រួញចិញ្ចើមភ្នាម, ទីងតុងសើច :

- ស្រានេះគេបិតទុកជាង ២០ ឆ្នាំហើយ, ឆ្ងាញ់ទេបង ?

ស៊ីផានមិនទាន់បានឆ្លើយផងស្រាប់តែឮសម្លេងមួយលាន់ពីលើស្ពានថ្មថា :

-ស្រាដែលអប់ទុកជាងម្ភៃឆ្នាំ ពិតជាមានរសជាតិឆ្ងាញ់ណាស់ ។

ហើយឮស្នូរតែច្រឹង គឺទីងតុងរបូតកែវស្រាពីដៃកំពប់លើខោប្រឡាក់អស់, កែវស្រាក់រមៀលធ្លាក់ក្នុងទឹកក្លុង ។ ទីងតុងភ័យស្លាំងមុខញ័រចំប្រប់កាន់ដៃស៊ីផានពោលតិច ៗ :

- ជីតាខ្ញុំមកដល់ហើយ !

សម្លេងដដែលបន្លឺពីលើក្បាលមកទៀត :

- អឺ ! ជីតាឯងមកដល់ហើយ ! មីចៅចង្រៃហ៊ានលបជួបសង្សារ ហើយហ៊ានលួចស្រាក្រអូបអញមកបំប៉នសង្សារទៀត !

ទីងតុងខំពោលតប :

– គាត់ . . គាត់មិនមែនសត្រូវអីទេ ... ជាមិត្តភក្តិធម្មតាតើលោកតា ។

តាចាស់ស្រែកគំហកពីលើមក :

– ហ៊ឹះ ! មិត្តភក្តិខ្មោចយក្សអី , ហ៊ានលួចស្រាដែលជាអាយុជីវិតជីតាឯងមកឲ្យវាហើយ , នៅហ៊ានប្រកែកឬ ? មើល ! អាកូនចោរអប្រិយ៍ចេញមកបង្ហាញយើងផង , មុខមាត់ឯងយ៉ាងម៉េច ? សក្តិសមនឹងចៅស្រីអញ ឬ ទេ ?

ស៊ីផានងើយក្បាលមើលរ៉ះប៉ះជើងតាចាស់ ដែលទម្លាក់ចុះមកយោលទៅយោលមកប្រផិតៗ ក្បាលគេម្តងៗ តាចាស់ពាក់ស្រោមជើងសស្គុស, ចិនគុនចាប់ដៃស៊ីផានសរសេរអក្សរញាប់ដៃ ហើយមាត់ចេះតែពោលទៅកាន់ជីតា:

--លោកតាអើយ ! មិត្តនេះល្ងង់ខ្លៅហើយអាក្រក់ណាស់លោកតាមិនពេញចិត្តទេ ! ខ្ញុំឥតឲ្យគាត់ផឹកស្រាលោកតាឯណា ? គ្រាន់តែហៅគាត់មកកំដរខ្ញុំទេតើ ! ខ្ញុំចង់ញ៉ាំស្រាលោកតាមួយកែវតូច . . .

ស៊ីផាន ដឹងថានាងសរសេរអក្សរលើបាតដៃ ហាមនាយមិនឲ្យនិយាយទទួលខ្លួនជានាយក្រុមគ្រហូលស៊ី, តែចំឡែកអ្វីនាងពោលខ្លាំងៗ ប្រាប់តាចាស់ថានាយល្ងង់ហើយអាក្រក់ ? នាយយល់ថាជាពាក្យបន្តុះបង្អាប់ក៏ខឹងខ្ញួលរលាស់ដៃនាងចោលភ្លាម ។ ចិនគុនកញ្ឆក់ដៃនាយមកសរសេរប្រាប់ទៀតថា ប្រយ័ត្នមានគ្រោះថ្នាក់ដល់ជីវិតត្រូវស្លាប់ខ្ញុំសិន ។ សរសេរចប់នាងច្របាច់ដៃដៃអ្នកកម្លោះយ៉ាងថ្នមបញ្ជាក់ចិត្តភក្តីស្រឡាញ់រាប់អានដោយស្មោះ ។ ស៊ីផានមិនយល់ទាល់តែសោះ, តាចាស់ដដែលពោលមកទៀត :

– អាក្មេងទាំងពីរឡើងមកឆាប់ឡើង! អាគុនថ្ងៃនេះសម្លាប់មនុស្សបានប៉ុន្មាននាក់ហើយ?

ចិនគុនញ័រមាត់ :

–ដូចជា... ដូច... ទើបបានម្នាក់ទេលោកតា!

ស៊ីផានគិតថា :

– ទៅណាមកណាឮតែគេពោលពីរឿងសម្លាប់មនុស្សដូចជាចំឡែកណាស់! ចិនគុនហាមមិនឲ្យយើងទទួលខ្លួនជានាយក្រុមស៊ីយើងយល់ព្រមព្រោះយើងមិនមែននាយក្រុម, តែ... នាងចង់យ៉ាងម៉េច ?

ពេលនេះតាចាស់ពោលបន្ត:

– បើទើបនឹងសម្លាប់បានម្នាក់យើងអាចសម្លាប់បានពីរនាក់ទៀត ! អើសម្លាប់មកក្លែមស្រា

ប្រហែលឆ្ងាញ់ ។

សុីផានទឹកថា:

- ក្នុងលោកនេះមានមនុស្សចង់សម្លាប់គេមកក្លែមស្រាដែរឬ ?

ស្រាប់តែទីងតុងលែងដៃនាយក្លាម ហើយនាយព្រិលភ្នែកឃើញដូចតាចាស់ល្ហោតមកឈរចន្លោះនាយនិងទីងតុង ។ តាចាស់មានទឹកមុខស្លូតបូតហើយញញឹមព្រាយ ។ គាត់មានមុខវែងតែឡើងមុខប៉ះភ្នែកគាត់កាលណា សុីផាន ក៏យញាក់ហប់កាលនោះ ព្រោះខ្សែភ្នែកគាត់មុតថ្លាចេញពន្លឺកាចសាហាវឥតអ្វីប្រៀបបាន, នរណាឃើញហើយច្បាស់ជាព្រឺក្បាលខ្លាក់ៗមិនខាន ។ តាចាស់សើចស្ញេញលូកដៃទះស្មាមាណពផាំងព្រមទាំងពោល

- អាប្រមឹកឯងមានសំណាងណាស់បានផឹកស្រាយើង ។

តាចាស់ទះមួយដៃលាន់ឮផ្លឹងប្រឹប ១ ហាក់ចង់បាក់បែក ធ្វើឲ្យទីងតុងភ័យជំនួសសុីផាន ។ នាងទាញដៃតាចាស់អង្វរ :

- សូមលោកតាកុំធ្វើបាបគាត់ ។

តាចាស់ទះមាណពប្រាថ្នាឲ្យបាក់ឆ្អឹង ឬ ដាច់សាច់របួសធ្ងន់ ។ តែនៅពេលបាតដៃគាត់ប៉ះស្មាអ្នកកម្លោះ គាត់ទទួលអារម្មណ៍ប្លែកដូចមានកម្លាំងអាថ៌កំបាំងរត់ចេញមកដេញខ្យល់ដៃគាត់ត្រឡប់វិញយ៉ាងសាហាវ ។ បើគាត់មិនប្រញាប់បន្ថែមថាមពលទេ ប្រហែលអាចយ៉ើងធ្លាក់ទឹកប៉ឹងផង ។

តាចាស់ប្រើកម្លាំងប្រាំពីរភាគហើយនៅទប់ទល់មាណពមិនបានគាត់ភ្ញាក់ផ្អើលជាងទីងតុងទៅទៀត តែគាត់នៅសើចហាស ៗ ពោលបន្ត :

- ល្អណាស់ ! អាប្រមឹកនេះមានសមត្ថភាពអាចផឹកស្រាយើងបាន ! អាតុងចាក់ស្រាមកទៀត ! មួងនេះតាឲ្យវាផឹក , តាមិនបន្ទោសទៅទេ !

ទីងតុងរីករាយជាអនេក ព្រោះធ្លាប់ដឹងថា ជីតានាងឆ្មើងឆ្មៃណាស់, សូម្បីកំពូលអ្នកក្លាហានក៏គាត់មិនខ្វីរាប់រកផង , ពេលនេះគាត់ហៅមាណពផឹកស្រាជាមួយបានសេចក្ដីថា គាត់ពេញចិត្តហើយ ។

នាងឆ្ងល់ដែរ ម្ដេចក៏លោកតាប្រែចិត្តរហ័សម៉េះ ? អម្បាញ់មិញគាត់ចង់សម្លាប់មនុស្សពីរនាក់ថែមទៀត , ឥឡូវហៅគេផឹកស្រា . . . បែបគាត់ឃើញមាណពជាសង្សារនាងមានរូបរាងស្រស់

សង្ហា មាឌមាំទេដឹង ?

ទឹងតុងឥតចាប់ភ្ញាក់នឹកដល់ការពិតទេ ។ អម្បាញ់មិញជីតានាងព្រៃថាសម្លាប់មាណពមែនតើ ! បើកុំតែការម្នាក់នេះគ្មានកម្លាំងជាតុស្តុកស្តម្ភប្រចាំកាយម៉្លេះនាយមានគ្រោះថ្នាក់ដល់ជីវិតហើយ ។ តាចាស់ឃើញកម្លាំងជាតុថ្លៃកទើបបន្ធូរស៊ិន, មិនមែនគាត់ពេញចិត្តនឹងមាណពទេ ។

ទឹងតុងវិតចូលក្នុងខ្ទមយកកែវស្រាពីរថែមទៀត ចាក់មួយកែវជូនជីតា មួយកែវទៀតឲ្យស៊ីផានខ្លួនឯងកាន់មួយកែវដែរ ។ តាចាស់ពោលដោយរីករាយ :

- ប្រសើរណាស់អាប្រមក់ ! អាតុងទៅឃើញពេញចិត្តឯង ច្បាស់ជាមានបុព្វហេតុអ្វីមួយហើយ មើលឯងឈ្មោះអី ?

ស៊ីផានឆ្លើយឥតរួចព្រៃ ខ្ញុំ... ខ្ញុំ ... ខ្ញុំ. . . ព្រោះនាយយល់ហើយថា «ផ្តែឥតពូជ» មិនមែនឈ្មោះមនុស្សហើយមិនល្អស្តាប់ទៀត ។ បើនិយាយលេងជាមួយមិត្តក៏គិតប្រហែលបានខ្លះ តែគេមិនត្រូវប្រាប់អ្នកចាស់ទុំដែលស្គាល់គ្នាដំបូង ដូចតាចាស់នេះទេ ។ តាចាស់មិនពេញចិត្តចាល់តែសោះ សួរភ្លាម :

- ឯងមិនហ៊ានប្រាប់តាឬ ?

ស៊ីផានងក់ក្បាល ។ តាចាស់សួរទៀត :

- ហេតុអីបានជាមិនហ៊ាន !

- ព្រោះឈ្មោះខ្ញុំមិនសូវពីរោះ ។ ខ្ញុំឈ្មោះផ្តែឥតពូជ !

តាចាស់ស្រឡាំងកាំងមួយខណៈ រួចក្លាយសំណើចភ្ញាក់ភ្អាយលាន់រំពងបឹងនិងដើមឈើជុំវិញ , ពុកមាត់គាត់សក្បុសប៉ុងគ្រប់ទិស ។ មួយសន្ទុះធំទើបគាត់ពោល :

-ល្អ ! ល្អ ! ឈ្មោះអាប្រមក់ឯងពីរោះណាស់តើ !

-បាទៗលោកតាហៅខ្ញុំមានការអី ?

ទឹងតុងញញឹមពព្រាយ សម្ងំមុខនាយក្រមស៊ុយ៉ាងពេញចិត្ត ព្រោះឮនាយហៅជីតាខាងថា « លោកតា » ពេញមាត់ ។ រីតាចាស់ក៏សប្បាយដែរ ព្រោះអ្នកខ្លាំងពូកែដូចមាណពធ្លាយនឹងគាត់បាទៗ ញាប់មាត់ហាក់ដូចខ្លបខ្លាចណាស់ ។ ត្បិតស៊ីផានជាផ្តែឥតពូជមែន ឥតចេះហៅឬនិយាយតាមចិត្តគំនិតខ្លួននឹកឃើញទេ ប្រុងតែស្តាប់អ្នកឯទៀតនៅជុំវិញប៉ុណ្ណោះ ។ កាល...

Khmer Story Lovers 

បើពួកគេហៅលោកតា, នាយហៅតាម, ពួកគេហៅអ្នកនាង នាយហៅដែរ ។

ទីនគុនរីករាយដោយទឹកថាជីតាពេញចិត្ត ពីនបុរសដែលនាងស្រឡាញ់, តាចាស់រីករាយដោយសារឿងផ្សេង, គិតទៅជីតានិងចៅយល់ឥតដូចគ្នាទេ ។

តាចាស់សួរចៅស្រី :

- អាគុនអ្ហា ! ឯងមានប្រាប់ឈ្មោះតាឲ្យសង្សារដឹងហើយនៅ ?

ទីនគុនគ្រវីក្បាលអៀនព្រៀន :

- ខ្ញុំមិនទាន់ប្រាប់ទេលោកតា ។

តាចាស់ប្រែទឹកមុខ :

- ចៅឯងស្រឡាញ់វាមែនទេ, ហេតុម៉េចមិនរប់រៀបប្រវត្តិប្រាប់វាផង ? បើមិនទាន់ស្រឡាញ់វាទេម៉េចហ៊ានលួចស្រាថ្នាំដែលតាខំរក្សាទុកស្មើជីវិតឲ្យអាប្រមក់ហ្នឹងផឹក ?

សំដីគាត់ពីនឡើងៗ ដូចគំហក ហើយនៅពេលពោលដល់ស្រាថ្នាំ, គាត់ បញ្ចេញពន្លឺភ្នែកដូចផ្លេកបន្ទោរបែងចាំងនៅពេលភ្លៀងធ្វើឲ្យមាណពព្រួយបារម្ភជាពន់ពេក ។ ទីនគុនខ្លាចណាស់, នាងទុនកាយឱបតាចាស់អង្វរទន់ភ្លន់ :

- លោកតាអ្ហា ! បើលោកតាជ្រាបអ៊ីចឹងហើយ សូមលោកតាអាណិតលើកលែងទោសឲ្យអាគុនផងណា !

តាចាស់ធ្វើហុះសួរវិញ :

- អត់ទោសអាគុនឬ ? និយាយដូចជាស្រួលណាស់ , តើចៅដឹងហើយស្គាល់គុណភាពស្រាថ្នាំតាដែរ ? ចៅយកមកផឹកលេងផ្ដេសផ្ដាសដូច្នេះ អស់របស់តាទៅងាយរកណាស់ ឬ ?

- បើលោកតាលើកទោសឲ្យចៅ , ចៅធានាប្រឹងប្រែងរកថ្នាំផ្សំជូនតាវិញទាល់តែបាន ។

- និយាយដូចជាស្រួលណាស់ទី ! បើរកថ្នាំបានងាយៗនោះតាមិនបាច់បន្ទោសចៅស្រីទេ !

- មកពីអាគុនចៅតាឃើញបងជានក្ដៅម្ដងត្រជាក់ម្ដងនោះណា បានជានឹកឃើញស្រាថ្នាំលោកតាក្រែងពូកែសក្ដិសិទ្ធិអាចជួយរំលាយធាតុក្ដៅនិងត្រជាក់ចម្លែកបាន ។ បងនេះផឹកស្រាបន្តិចម្ដងៗ ទាល់តែអស់មិនដឹងខ្លួន, ឥឡូវលោកតាជួយប្រាប់អាគុនចុះ ត្រូវការឫសឈើឬវត្ថុអ្វីខ្លះ ? ទោះលួចប្លន់ក៏អាគុនស្វះស្វែងរកឲ្យគ្រប់មកផ្សំមួយដបជូនលោកតាវិញដែរ ។ **(នៅមានត)**

ដំកល់ទុកតាមលេខ ៣០៦ ចុះថ្ងៃទី ២២-៥-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់